ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ

លេខ៖៣៥/១៤-០១-២០១៤

សាលដីកា

លេខ៖៦៦ក្រIVអ/១២-៩-២០១៤

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រម លេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ ២០១៤ បានបើកសវនាការជាសាធារណៈ នៅសាលាឧទ្ធរណ៍ នាថ្ងៃទី ១២-៩-២០១៤ ដែលមានសមាសភាពដូចតទៅ៖

## សមាសភាពក្រុមប្រឹក្សា

លោក [redacted] ជាប្រធាន

លោក [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

## តំណាងមហាអយ្យការ

លោក [redacted]

## ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ នៃរឿងព្រហ្មទណ្ឌ លេខ ៣៥ ចុះថ្ងៃទី១៤-០១-២០១៤ **រវាងជនជាប់ចោទ :**

-ឈ្មោះ [redacted] ខៀប (អ៊ន) ភេទប្រុស អាយុ៣១ឆ្នាំ ជាតិខ្មែរ មុខរបរជាងឈើ ទីកន្លែងកំណើត [redacted] ទីលំនៅសព្វថ្ងៃនៅ [redacted] ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] មានកូន០២នាក់ ទោសពីមុនគ្មាន ។

-មេធាវីលោក [redacted] វិបុល ការពារសិទ្ធិឱ្យជនជាប់ចោទ ។

**ជាប់ចោទពីបទ: រំលោភសេពសន្ថវៈ** តាមបញ្ញត្តិមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ប្រព្រឹត្តនៅភូមិពោធិ៍មាស ឃុំត្រពាំងជោរ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១២ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទស្រី អាយុ៣៦ឆ្នាំ ទីលំនៅសព្វថ្ងៃភូមិ [redacted]

[redacted] ។

**៦រឿងហេតុមានដូចតទៅ**

កាលពីថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១២ វេលាម៉ោង ២៤ យប់ នៅចំណុចផ្ទះរបស់ជនរងគ្រោះឈ្មោះ [redacted] ម៉ុន ស្ថិតនៅភូមិពោធិ៍មាស ឃុំត្រពាំងជោរ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ មានករណីរំលោភសេពសន្ថវៈ បង្កឡើងដោយជនសង្ស័យឈ្មោះ [redacted] ខៀប នៅខណៈដែលជនសង្ស័យរូបនេះបានផឹកស្រាស្រវឹង ហើយក៏ធ្វើសកម្មភាពចាប់រំលោភលើជនរងគ្រោះឈ្មោះ [redacted] ម៉ុន រហូតបានសម្រេច បន្ទាប់មកប្តីរបស់ជនរងគ្រោះក៏មកទាន់ ក៏ប្តឹងសមត្ថកិច្ចឱ្យឃាត់ខ្លួនជនល្មើសតែម្តង ។

បានឃើញសាលក្រមព្រហ្មទណ្ឌ លេខ ២៥៤ (ឥ) ចុះថ្ងៃ៣០ តុលា ២០១៣ របស់សាលាដំបូងខេត្តកំពង់ស្ពឺ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចខាងក្រោម៖

១/ផ្តន្ទាទោសឈ្មោះ [redacted] ខៀប (អ៊ិន) ភេទប្រុស អាយុ៣១ឆ្នាំ (មានសាវតាជាតិ) ដាក់ពន្ធនាគារកំណត់ចំនួន០៨ឆ្នាំ (ប្រាំបីឆ្នាំ) គិតពីថ្ងៃឃុំខ្លួនពីបទ *រំលោភសេពសន្ថវៈ* បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ប្រព្រឹត្តនៅ ភូមិពោធិ៍មាស ឃុំត្រពាំងជោរ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ កាលពីថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១២ ។

២/បង្គាប់អោយឈ្មោះ [redacted] ខៀប (អ៊ិន) សងជម្ងឺចិត្តជាប្រាក់ចំនួន ១.០០០.០០០៛ (មួយលានរៀល) ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណី និងជាជនរងគ្រោះឈ្មោះ [redacted] ម៉ុន នៅពេលសាលក្រមចូលជាស្ថាពរ សំណូមពរលើសពីនេះបដិសេធចោល ។

-ករណីឈ្មោះ [redacted] ខៀប (អ៊ិន) រឹងរូសពុំព្រមសងប្រាក់ពិន័យ ត្រូវដាក់គុកបង្ខំរូបរាងកាយតាមច្បាប់ ។

៣/សាលក្រមនេះបានជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ម៉ុន ។

បើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

សាលក្រមនេះត្រូវបានឈ្មោះ [redacted] ខៀប ប្តឹងឧទ្ធរណ៍តាមពាក្យបណ្តឹង ចុះថ្ងៃ០២ ធ្នូ ២០១៣ គ្រប់ចំណុចទាំងមូល នៃសេចក្តីសម្រេច ។

-បានឃើញរបាយការណ៍ របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ ចុះថ្ងៃទី២៦ ខែ៦ ឆ្នាំ២០១៤ ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ចុះថ្ងៃទី១៥ ខែ៧ ឆ្នាំ២០១៤ ។

**នាពេលសវនាការ**

-ជនជាប់ចោទឈ្មោះ [redacted] ឡៀប ហៅ អ៊ិន (វត្តមាន)

-មេធាវីលោក [redacted] វិបុល ការពារសិទ្ធិឱ្យជនជាប់ចោទ (វត្តមាន)

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ម៉ុន (អវត្តមាន)

-ប្រធានក្រុមប្រឹក្សាអានសេចក្តីសុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌ លេខ ២៥៤(ឆ) ចុះថ្ងៃ ៣០ តុលា ២០១៣ របស់ជនជាប់ចោទឈ្មោះ [redacted] ឡៀប ហៅ អ៊ិន ធ្វើឡើងលើស ៣ ថ្ងៃ មិនអាចទទួលជំនុំជម្រះបាន ព្រោះហួសកំណត់ច្បាប់ ។

-**តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋាន៖** ក្នុងរឿងនេះ ឃើញថា បណ្តឹងឧទ្ធរណ៍លេខ ៦០ ចុះថ្ងៃ០២ ធ្នូ ២០១៣ របស់ជនជាប់ចោទឈ្មោះ [redacted] ឡៀប ហៅ អ៊ិន ធ្វើឡើងហួសកំណត់ច្បាប់ មិនអាចទទួលយកបាន សុំក្រុមប្រឹក្សាសម្រេចតាមច្បាប់ចុះ ។

-មេធាវីលោក [redacted] វិបុល ការពារសិទ្ធិជនជាប់ចោទសន្និដ្ឋានៈ ក្នុងរឿងនេះ សាលក្រមព្រហ្មទណ្ឌប្រកាសថ្ងៃ៣០ តុលា ២០១៣ ហើយកូនក្តីខ្ញុំបានប្តឹងឧទ្ធរណ៍នៅថ្ងៃ០២ ធ្នូ ២០១៣ គឺលើសកំណត់ច្បាប់ចំនួន ៣ថ្ងៃ ពិតមែន សុំប្រធានក្រុមប្រឹក្សា និងក្រុមប្រឹក្សាសម្រេចតាមច្បាប់ ។

-ក្រោយពីបានស្តាប់តំណាងមហាអយ្យការសន្និដ្ឋាន ។

-ក្រោយពីបានស្តាប់មេធាវីការពារសិទ្ធិជនជាប់ចោទសន្និដ្ឋាន ។

-ក្រោយពីបានពិនិត្យឯកសារពាក់ព័ន្ធល្អិតល្អន់ ។

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ ។

**<u>សាលាឧទ្ធរណ៍</u>**

**<u>-យល់ឃើញថាៈ</u>**

-បណ្តឹងឧទ្ធរណ៍លេខ ៦០ ចុះថ្ងៃ០២ ធ្នូ ២០១៣ របស់ជនជាប់ចោទឈ្មោះ [redacted] ឡៀប ធ្វើឡើងហួសកំណត់ច្បាប់ យោងតាមបញ្ញត្តិមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ សាលាឧទ្ធរណ៍ មិនអាចទទួលយកបាន ។

**<u>ហេតុដូចនេះ ទនិច្ឆ័យសេចក្ត</u>**

១/មិនអាចទទួលយកបានបណ្តឹងឧទ្ធរណ៍ លេខ៦០ ចុះថ្ងៃ០២ ធ្នូ ២០១៣ របស់ជនជាប់ចោទឈ្មោះ ឈើន ឡៀប ដោយហួសកំណត់ច្បាប់ តាមមាត្រា ៤០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២/សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខមេធាវី និងជនជាប់ចោទ បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

សេចក្តីនេះព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មក មន្ត្រីទទួលបន្ទុក អនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ច គ្រប់ថ្នាក់ គ្រប់តំណែង និងកំលាំងប្រដាប់អាវុធ ជួយសហការ អនុវត្តសាលដីកានេះឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជំរះ |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted] [redacted] | ហត្ថលេខា [redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ,ថ្ងៃទី[illegible]ខែ[illegible]ឆ្នាំ២០១៥

បានឃើញ

ប្រធានសាលាឧទ្ធរណ៍

[redacted]

ក្រឡាបញ្ជី

[redacted]